<u>របៀបធ្វើផ្ទាំងសំរាប់តាំងជានិមិត្តរូប</u>

មនុស្សគ្រប់គ្នាបានធ្វើផ្ទាំងសំរាប់តាំងជានិមិត្តរូប សំរាប់កម្មវិធី the NAMES Project AIDS Memorial Quilt ជាច្រើនរបៀបមានពណ៌ចម្រុះគ្នានិងធ្វើពីផ្ទាំងក្រណាត់ប្លែកៗ។ល។ ការធ្វើផ្ទាំងសំរាប់តាំងជានិមិត្តរូបនេះ គឺលោក-អ្នកមិនចាំបាច់ជាអ្នកពូកែដេរប៉ាក់ឬមានបច្ចេកទេសខាងធ្វើផ្ទាំងសំរាប់តាំងជានិមិត្តរូបនេះទេ។ លោក-អ្នកចង់ប្រើជក់និងថ្នាំលាបពណ៌ឬប្រើម្ជុលដេរដៃក៏មិនខាស់អ្វីដែរ។ លោក-អ្នកអាចធ្វើការតុបតែងផ្ទាំងសំរាប់តាំងជានិមិត្តរូបនោះតាមការសមរម្យនិងយល់ឃើញថាអ្វីៗអានុស្សាវរីយចំពោះវិញ្ញាណខ័ណ្ឌ នៃអ្នកស្រឡាញ់សំណប់ចិត្តដែលបានបាត់បង់ជីវិតទៅហើយនោះ។ ប៉ុន្តែយើងសូមមេត្តាចិត្តលោក- អ្នកឲ្យធ្វើទៅតាមរបៀបធ្វើតាមគំរូផ្ទាំងសំរាប់តាំងជានិមិត្តរូបពីមុនមកគឺមានការរាប់បញ្ចូលញាតិមិត្តនិងអ្នកដែលធ្លាប់ធ្វើការជាមួយសព នោះ។

នេះគឺជាគំរូនៃរបៀបបង្កើតនិងតុបតែងផ្ទាំងសំរាប់តាំងជានិមិត្តរូប

របៀបតុបតែងផ្ទាំងសំរាប់តាំងជានិមិត្តរូបមនុស្សដែលស្លាប់៖

* ដាក់ឈ្មោះមិត្តឬគូរសង្សារ
* ដាក់ថ្ងៃកំណើត ថ្ងៃដែលមនុស្សស្លាប់ ឈ្មោះស្រុកកំណើត។ល។
* សូមធ្វើផ្ទាំងសំរាប់តាំងជានិមិត្តរូបនេះមួយ សំរាប់មនុស្សម្នាក់

ការជ្រើសរើសក្រណាត់សំរាប់ធ្វើ

* ត្រូវចងចាំថាផ្ទាំងសំរាប់តាំងជានិមិត្តរូបនេះ ត្រូវបត់ជាផ្នត់ឬមូរជាច្រើនដង ដូច្នេះ ត្រូវធ្វើ ឲ្យបានក្រាស់ជាប់មាំ ។
* ត្រូវប្រើក្រណាត់ដែលមានទម្ងន់មធ្យម. ក្រាស់. មាំ មិនយឺត ដូចជាក្រណាត់ធ្វើពីកប្បាស។
* ផ្ទាំងក្រណាត់របស់អ្នក

អ្នកអាចធ្វើបណ្ដោយឬទទឹងក្រណាត់ក៏បាន។ ប៉ុន្តែនៅពេលជុល **ហើយ ត្រូវឲ្យមានទំហំ ទទឹង ៣ហ្វីត** បណ្ដោយ៦ហ្វីត (៩០ស.ម.x ១៨០សម) មិនឲ្យតូចជាងឬធំជាងកំណត់នេះទេ ។ នៅពេលកាត់ក្រណាត់អ្នកត្រូវកាត់ឲ្យលើសពី២ទៅបីអ៊ីងពីម្ខាងទៅម្ខាងដើម្បីទុកបត់ដេរ។ បើអ្នកចេះដេរភ្ជាប់ ជាការប្រសើរ បើអ្នកមិនចេះដេរយើងអាចដេរភ្ជាប់ឲ្យបាន។ ដេរទ្រាប់ខាងខ្នងផ្ទាំងក្រណាត់ ជាការចាំបាច់ ដើម្បីជួយកុំឲ្យផ្ទាំងក្រណាត់ទាំងមូលប្រឡាក់ នៅពេលលាផ្ទាល់នឹងដី។ម្យ៉ាងទៀតអាចជួយការពារ រាងក្រណាត់ឲ្យនៅដូចដើមបាន។

ការដេរប៉ាក់ផ្ទាំងក្រណាត់នេះ

**អ្នកត្រូវដេរតាមក្បួនខាងក្រោមនេះ ៖**

**ការរៀបចំ ៖**
ដេរក្រណាត់អក្សរនិងវត្ថុអានុស្សាវរីយ៍តូចៗភ្ជាប់នឹងក្រណាត់កុំប្រើជ័របិទវាមិនជាប់ល្អទេ។

**ការគូរ ៖**
គូរលើផ្ទាំងក្រណាត់ដោយប្រើថ្នាំពណ៌ដែលឆាប់ស្ងួតឬប្រើប៉ាក្កាជក់ធំសម្រាប់គូរកុំប្រើថ្នាំលាបក្រាស់ ព្រោះវាស្អិតពេក។

**ការប្រើក្រដាសពុម្ព ៖**
យកខ្មៅដៃគូសតាមទម្រង់ក្រដាសពុម្ពរួចហើយប្រើជក់លាប. ប៉ាក្កាជក់ធំ ឬ ប៊ិច ហ្វឺត ។

**រូបសិល្បៈផ្សេងៗ ៖**
ត្រូវប្រុងប្រយ័ត្ន រូបដែលអ្នកនឹងដេរភ្ជាប់ទៅនឹងផ្ទាំងក្រណាត់អាចធ្វើឲ្យរហែកក្រណាត់បាន(ជៀសវាងកុំប្រើរូបសិល្បៈណាដែលធ្វើពីជាតិកញ្ចក់ព្រោះនាំឲ្យរហែកក្រណាត់បាន)។ជៀសវាងកុំប្រើរបស់សិល្បៈណាដែល ធ្វើឲ្យសំពេងសំពោងពេក ។

**រូបថត ៖**
ជាការល្អយករូបថត ឬសំបុត្រទៅថតចម្លងទៅនឹងក្រដាសដែលអាចអ៊ុតភ្ជាប់ ទៅនឹងក្រណាត់ដែលមានជាតិកប្បាស១០០ភាគរយ(១០០%)រួចហើយកាត់យកទៅដេរភ្ជាប់នឹងផ្ទាំងក្រណាត់។(កុំដេរភ្ជាប់នឹងជ្រុងផ្ទាំងក្រណាត់ ព្រោះវានាំឲ្យបាក់រូបថតនៅពេលអ្នកបត់ផ្ទាំងក្រណាត់) ។

**ចំណាយពេលសរសេរសំបុត្រមួយ ឬពីរទំព័រ អំពីមនុស្សដែលអ្នកចង់រំលឹក ។**
សំបុត្រអ្នកអាចនិយាយពីទំនាក់ទំនងទៅអ្នកនោះ ថាតើអ្នកនោះចង់ឲ្យអ្នករំលឹកអំពីខ្លួនយ៉ាងណានិងអំពីអានុស្សាវរីយ៍ដែលសំខាន់ដល់អ្នក ។

**សូមកុំភ្លេចផ្តល់ពត៌មានអំពីអ្នកដែលធ្វើផ្ទាំងក្រណាត់ ដោយបំពេញពត៌មានក្នុងកាតខាងក្រោមនេះ ។**

**បើអ្នកអាចធ្វើ វិភាគទានបាន សូមជួយធ្វើវិភាគទានខ្លះ ដើម្បីជួយដល់តម្លៃ ក្នុងការធ្វើផ្ទាំងក្រណាត់ (Quilt) ។**

The NAMES Project Foundation សង្ឃឹមលើការជួយគាំទ្រដល់អ្នកដែលចូលរួមក្នុងការធ្វើផ្ទាំងក្រណាត់នេះដើម្បីរក្សាផ្ទាំងក្រណាត់ និងតាំងផ្ទាំងក្រណាត់ឲ្យសាធារណៈជនបានឃើញ ។ វិភាគទានជំនួន ២៥០ដុល្លា ឡើងទៅ យើងនឹងរំលឹកឈ្មោះអ្នកធ្វើអំណោយនៅក្នុងសេចក្តីរាយការណ៍ប្រចាំឆ្នាំ របស់យើង ។

ខ្ចប់របស់ទាំងអស់ដោយប្រុងប្រយ័ត្ន ផ្ញើរទៅ ៖

NAMES Project Rhode Island
P. O. Box 2591
Newport, RI 02840
ដើម្បីពត៌មានផ្សេងៗ សូមទូរស័ព្ទ :
(៤០១) ៨៤៧-៧៦៣៧

